# ការធ្វើបទបង្ហាញពីការវិវត្តន៍របស់តុលាការខ្មែរក្រហមនិងគេហទំព័រឃ្លាំមើលការកាត់ទោសមេដឹកនាំខ្មែរក្រហមនៅសកលវិទ្យាល័យវេស្ទើន

និត្យ ធរណ្ណារាណ



និស្សិតសាកលវិទ្យាល័យវេស្ទើនស្តាប់បទបង្ហាញ

*"ខ្ញុំបានដឹងជាច្រើនតាមរយៈសិក្ខាសាលានេះ ។ ការកាត់ទោសមេដឹកនាំខ្មែរក្រហមគឺជាការព្រមានមួយដើម្បីកុំឲ្យក្មេងជំនាន់ក្រោយយកគំរូតាមនិងជឿថារបបនេះពិតជាកើតមានឡើងពិតប្រាកដ" ។*

**ជី ស្រីស្រស់ និស្សិតឆ្នាំទី១ ផ្នែកធនាគារ**

កាលពីថ្ងៃទី៨ ខែវិច្ឆិកា ឆ្នាំ២០១២ ក្រុមការងាររបស់មជ្ឈមណ្ឌលឯកសារកម្ពុជាបានចុះទៅធ្វើការផ្សព្វផ្សាយដំណើរវិវត្តន៍របស់តុលាការខ្មែរក្រហម និងគេហទំព័រឃ្លាំមើលការកាត់ទោសមេដឹកនាំខ្មែរក្រហមនៅសកលវិទ្យាល័យ វេស្ទើន ទីក្រុងភ្នំពេញ ។ ការចុះទៅផ្សព្វផ្សាយពីគេហទំព័រនេះគឺក្នុងគោលបំណងឲ្យនិស្សិតបានយល់ដឹងអំពីដំណើការកាត់ទោសមេដឹកនាំខ្មែរក្រហម ពិសេសគឺងាយស្រួលដល់និស្សិតក្នុងការធ្វើការស្រាវជ្រាវទៅលើអត្ថបទច្បាប់ វីដេអូនិងព័ត៌មានទាំងឡាយដែលទាក់ទងនឹងតុលាការនេះ ។

*វេទិកាពិភាក្សាបានប្រព្រឹត្តទៅចាប់ពីម៉ោង៩ព្រឹកដល់ម៉ោង១២ថ្ងៃត្រង់ ដោយមាននិស្សិតចូលរួមជាង១០០នាក់ ដែលភាគច្រើនជានិស្សិតរៀនថ្នាក់មូលដ្ឋាន ។ ចំនួននិស្សិតចូលរួមគឺមានចំនួនលើសពីអ្វីដែលយើងបានរំពឹងទុក ហើយនិស្សិតហាក់ដូចជាមាន ការយល់ដឹងច្រើនពីប្រវត្តិសាស្ត្រខ្មែរក្រហមនិងដំណើរការកាត់ទោសមេដឹកនាំខ្មែរក្រហម ទោះបីជាគ្មានវត្តមានរបស់និស្សិតច្បាប់ក៏ដោយ ។*

**ការបញ្ចាំងកុនឯកសាររឿង «គុកទួលស្លែងក្នុងឆ្នាំ១៩៧៩»**

*បន្ទាប់ពីក្រុមការងាររបស់មជ្ឈមណ្ឌលឯកសារកម្ពុជាបានចែកឯកសារមួយចំនួនទាក់ទងទៅនិងប្រវត្តិសាស្ត្រខ្មែរក្រហមនិងដំណើរការកាត់ទោសមេដឹកនាំខ្មែរក្រហម ដូចជា សៀវភៅកម្ពុជាប្រជាធិបតេយ្យ សៀវភៅសង្ខេបការណ៍ការកាត់ទោសមេដឹកនាំខ្មែរក្រហម និងឯកសារដែលបង្ហាញពីគន្លឹះនៃការស្វែងរកឯកសារនានាក្នុងគេហទំព័រឃ្លាំមើលការកាត់ទោសមេដឹកនាំខ្មែរក្រហមរួចមក ។ ម៉ុក ភីរក្ស អ្នកទទួលបន្ទុកកិច្ចការងារនិស្សិតនៃសាកលវិទ្យាល័យវេស្ទើនបានថ្លែងបើកកម្មវិធីណែនាំពីមជ្ឈមណ្ឌលឯកសារកម្ពុជានិងផ្តាំផ្ញើទៅកាន់និស្សិតទាំងអស់ឲ្យយកចិត្តទុកដាក់ស្តាប់ដើម្បីស្វែងយល់ពីប្រវត្តិខ្មែរក្រហមដែលជាផ្នែកមួយនៃប្រវត្តិសាស្ត្រប្រទេសកម្ពុជា ។*

*ជាកិច្ចបន្ត លី សុខឃាង ដែលជាអ្នកប្រឹក្សាមួយរូបក្នុងគម្រោងមួយរបស់មជ្ឈមណ្ឌលឯកសារកម្ពុជា ដែលធ្វើការបណ្តុះបណ្តាលលោកគ្រូ-អ្នកគ្រូជាច្រើនរូបអំពីរបបកម្ពុជាប្រជាធិបតេយ្យ បានឡើងមកណែនាំខ្លួនម្តងទៀត និងក្រុមការងារទៅកាន់និស្សិតទាំងអស់គ្នា ។ សុខឃាង បានចាក់បញ្ចាំងនូវខ្សែភាពយន្តឯកសារមួយជូននិស្សិតទស្សនា ។ កុនឯកសារនេះថតដោយអ្នកកាសែតរបស់វៀតណាមពីរនាក់គឺ ហូ វ៉ាន់ថាយ និង ឌីញ ភូង នៅថ្ងៃទី១០ មករា ឆ្នាំ១៩៧៩ ។*

*និស្សិតគ្រប់ៗរូបបានធ្វើការយកចិត្តទុកដាក់មើលទៅលើកុនឯកសារនោះ ដែលហាក់ដូចជារឿងថ្មីមួយដែលខ្លួនពុំធ្លាប់ធ្លាប់បានជួបប្រទះសោះ ។ និស្សិតខ្លះបានសម្តែងនូវភាពភ័យខ្លាចចំពោះរូបភាពនៅក្នុងកុនឯកសារមួយនេះ ហើយសិស្សខ្លះបានធ្វើការពិភាក្សាគ្នាចំពោះភាពយន្តនោះ ដែលហាក់ដូចជាកំពុងរៀបរាប់ពីសាច់រឿងនៅក្នុងភាពយន្តនោះទៅមិត្តភក្តិដែលកំពុងអង្គុយជិតខ្លួន ។*

**ការធ្វើបទបង្ហាញត្រួសៗពី មជ្ឈមណ្ឌលឯកសារកម្ពុជា និងប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ**

*ក្រោយពីទស្សនាភាពយន្តឯកសារ ដែលមានរយៈពេលប្រហែល៧នាទី នោះមកលោក សុខឃាង បានចាប់ផ្តើមផ្តល់បទបង្ហាញអំពីប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ ។ មុននឹងចាប់ផ្តើមលោក សុខឃាង បានធ្វើការណែនាំដោយសង្ខេបពីការកកើតនៃមជ្ឈមណ្ឌលកសារកម្ពុជា និងអណត្តិរបស់ខ្លួនក្នុងការអនុវត្ត*

នូវបេសកម្មដែលប្រមែប្រមូល និងរៀបចំចងក្រងរក្សាទុកនូវឯកសារប្រវត្តិសាស្ត្រនៃរបបខ្មែរក្រហម សម្រាប់បម្រើទុកជាប្រវត្តិសាស្ត្រផង និងសម្រាប់ទុកជាភស្តុតាងផង ។

បទង្ហាញរបស់លោកបណ្តាលឲ្យមានការចោទជាសំណួរជាច្រើនពីសំណាក់និស្សិតដែលអាចឆ្លុះបញ្ចាំងឲ្យឃើញថា និស្សិតទាំងអស់នោះមានការចាប់អារម្មណ៍ជាខ្លាំង និងចង់ដឹងពូរវាងប្រវត្តិសាស្ត្រខ្មែរក្រហម និងដំណើរការនីតិវិធីនៅក្នុងសាលាក្តីខ្មែរក្រហម ។

និស្សិតនារីម្នាក់បានលើកដៃ និងក្រោកឈរមុនគេ ដើម្បីសួរទៅកាន់លោក សុខឃាង ពីគោលបំណងនៃការបង្អត់អាហារ និងសម្លាប់ប្រជាជននៅក្នុងរបបខ្មែរក្រហម ។ ហើយសំនួរបន្តបន្ទាប់របស់និស្សិតផ្សេងៗទៀតគឺមានភាពប្រហាក់ប្រហែលគ្នាដូចជា មានការចោទសួរអំពី ការកើតឡើងពីរបបនេះ ឬក៏នយោបាយនៃការដិះជាន់វណ្ណៈមូលធននិងសក្តិភូមិជាដើម ។ សំនួរអំពីបញ្ហាទាំងនេះ ត្រូវបានឆ្លើយទៅវិញយ៉ាងក្បោះក្បាយដោយលោក សុខឃាង ដែលពន្យល់តាំងពីការកកើតដំបូងរបស់ខ្មែរក្រហម ផែនការ៤ឆ្នាំរបស់ខ្មែរក្រហមជាដើម ។ ស្របពេលនឹងលោក សុខឃាង និយាយពីបញ្ហាដែល ខ្មែរក្រហមមិនទុកចិត្តគ្នាឯង និងបែងចែកសត្រូវជា២ប្រភេទនោះ មាននិស្សិតម្នាក់ស្ម័គ្រចិត្តរៀបរាប់អំពី ថានរណាដែលជាសត្រូវខាងក្រៅរបស់ខ្មែរក្រហមខ្លះនោះ ។



និស្សិតស្តាប់បទបង្ហាញ



អំឡុងពេលដែលនិស្សិតងើបឡើងដើម្បីដាក់សំនួរពីរឿងប្រវត្តិសាស្ត្រខ្មែរក្រហមដដែលៗបណ្តាក់គ្នាពីនិស្សិតម្នាក់ទៅម្នាក់រំពេចនោះក៏មានសំនួរមួយផុសចេញមកទាក់ទងនឹងតុលាការអំពីសំណុំរឿង០០៣ និង០០៤ ។ ដូច្នេះដើម្បីជាការឆ្លើយតបនូវសំនួរនេះលោក សុខឃាង បានផ្តល់តួនាទីដើម្បីធ្វើបទបង្ហាញ

ពីបញ្ហាដែលទាក់ទងនេះទៅ កញ្ញា ឆាយ ឈុនលី សមាជិកនៃក្រុមសង្កេតការណ៍ការកាត់ទោសមេដឹកនាំខ្មែរក្រហម ។

## បទបង្ហាញអំពីដំណើរការកាត់ទោសមេដឹកនាំខ្មែរក្រហមនៃសំណុំរឿង០០២

កញ្ញា ឆាយ ឈុនលី បានឆ្លើយតបទៅនឹងសំណួរទាក់ទងនឹងបញ្ហានៃការបន្តសំណុំរឿង០០៣ និង០០៤ ដែលនិស្សិតបានចោទសួរខាងលើថា តុលាការអាចនឹងបន្ត ពីព្រោះការតែងតាំងបានធ្វើរួចសព្វគ្រប់ហើយ ចំពោះចៅក្រម និងមេធាវី ។ សព្វថ្ងៃ សំណុំរឿង០០៣ និង០០៤ កំពុងស្ថិតនៅក្នុងដំណាក់កាលស៊ើបអង្កេតបន្ថែមនៅឡើយ ។

ជាមួយគ្នានេះដែរ កញ្ញា ឈុនលី ក៏បានរៀបរាប់ពីសំណុំរឿង០០២ ដែលកំពុងមានភាពស្មុគស្មាញជាខ្លាំងនៅឯអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា និងជាសំណុំរឿងដែលធ្វើឲ្យជនរងគ្រោះក៏ដូចជា បណ្តាអ្នកតាមដានទាំងក្នុង និងក្រៅប្រទេសទាំងអស់មានការព្រួយបារម្ភយ៉ាងខ្លាំងទៅលើអសមត្ថភាពខាងផ្នែកកាយសម្បទារបស់ជនជាប់ចោទ ។ ថ្មីៗនេះ ស្ថានភាពសុខភាពរបស់ជនជាប់ចោទ អៀង សារី កំពុងមានបញ្ហាយ៉ាងធ្ងន់ធ្ងរ ដែលធ្វើឲ្យបុគ្គលិករបស់តុលាការមានភាពមមាញឹក ហើយក៏ពុំអាចរៀបចំកាលវិភាគបានទៀងទាត់ ដូច្នេះទើប ក្រុមការងាររបស់មជ្ឈមណ្ឌលឯកសារកម្ពុជាយើង បានចុះទៅធ្វើការផ្សព្វផ្សាយនៅតាមបណ្តាសកលវិទ្យាល័យទូទាំងប្រទេសពីការវិវត្តន៍របស់តុលាការ និងគេហទំព័រដែលសិស្សនិស្សិតអាចស្វែងរកនូវឯកសារ ពត៌មាន និងវីដេអូទាំងស្រុងពីសវនាការ ។

ទោះបីជាគ្មានវត្តមានរបស់និស្សិតច្បាប់នៅក្នុងនោះ ប៉ុន្តែនិស្សិតខ្លះហាក់ដូចជាបានតាមដាននឹងរឿងតុលាការនេះមិនអន់ប៉ុន្មានដែរ ។ ស្របពេលកញ្ញា ឈុនលី កំពុងតែធ្វើបទបង្ហាញពីតួនាទីរបស់ជនជាប់ចោទទាំង៤រូប និងបញ្ហាកាយសម្បទារបស់អៀង ធីរិទ្ធ និស្សិតដែលអង្គុយនៅខាងមុខមួយចំនួនបាននិយាយសំរបគ្នានឹងអ្វីដែល កញ្ញា ឈុនលី កំពុងនិយាយដែលស្តាប់មើលទៅដូចជា សិស្សបានដឹងមុនពីអ្វីដែលគ្រូរបស់ខ្លួនកំពុងបង្រៀន ។ ចំពោះការធ្វើបទបង្ហាញនេះ កញ្ញា ឈុនលី បានលើកឡើងពីបញ្ហាកាយសម្បទារបស់ជនជាប់ចោទ អៀង ធីរិទ្ធ ដែលបានដោះលែងដោយតុលាការ តាមលក្ខខណ្ឌបណ្តោះអាសន្នហើយកញ្ញា ឈុនលី ក៏បានប្រាប់ពីសេចក្តីជូនដំណឹងមួយផងដែរ ចំពោះសវនាការលើសេចក្តីសម្រេចពាក់ព័ន្ធនឹងលក្ខខណ្ឌនៃការដោះលែងជនជាប់ចោទ អៀង ធីរិទ្ធ នៅថ្ងៃទី ១៣ វិច្ឆិកា ខាងមុខនេះ ។

សព្វថ្ងៃនេះ កិច្ចដំណើរនីតិវិធីក្នុងសវនាការ ស្ថិតក្នុងអង្គហេតុទី៣ ក្នុងដំណាក់កាលទី១ នៃសំណុំរឿង០០២ ប៉ុន្តែតុលាការកំពុងតែមានបញ្ហាដែលពិបាកធ្វើឲ្យកិច្ចដំណើរការនីតិវិធីប្រព្រឹត្តទៅដោយរលូន ពីព្រោះជនជាប់ចោទ អៀង សារី កំពុងតែមានអាការៈកាន់តែធ្ងន់ធ្ងរទៅៗ ។

## កញ្ញា ជា ផល្លា បកស្រាយអំពីគេហទំព័រការឃ្លាំមើលការកាត់ទោសមេដឹកនាំខ្មែរក្រហម

កញ្ញា ជា ផល្លា ប្រធានក្រុមនៃគេហទំព័រឃ្លាំមើលការកាត់ទោសមេដឹកនាំខ្មែរក្រហមបានផ្តល់បទបង្ហាញពីគេហទំព័រទៅកាន់និស្សិតដើម្បីឲ្យនិស្សិតមានការយល់ដឹង និងចេះស្រាវជ្រាវព័ត៌មានដែលមាននៅក្នុងគេហទំព័រ ។ ដើម្បីស្វែងយល់កាន់តែច្បាស់ពីដំណើរការវិវត្តន៍របស់សាលាក្តីខ្មែរក្រហមកញ្ញា ជា ផល្លា បានចាប់ផ្តើមបទបង្ហាញរបស់ខ្លួនថាគេហទំព័រឃ្លាំមើលសាលាក្តីខ្មែរក្រហមនេះគឺជាប្រភពដ៏សំខាន់ដែល និស្សិតគួរតែចាប់អារម្មណ៍ ហើយគេហទំព័រឃ្លាំមើលការកាត់ទោសមេដឹកនាំខ្មែរក្រហមជាគេហទំព័រដែល ទទួលការអនុញ្ញាតិ ពីអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាឲ្យផ្សព្វផ្សាយព័ត៌មានដល់សាធារណជន ។



ការបង្ហាញពីគេហទំព័រការឃ្លាំមើលសាលាក្តីខ្មែរក្រុហម

គេហទំព័រនេះមានផ្ទុកទៅដោយឯកសារដូចជារបាយការណ៍ប្រចាំថ្ងៃនៅសវនាការ វីដេអូរបស់សវនាការ អត្ថបទវិភាគរបស់បញ្ញាវ័ន្ត ឯកសារប្រវត្តិសាស្រ្តផ្សេងៗទៀតទាក់ទងនឹងប្រវត្តិសាស្រ្តខ្មែរក្រហម និងដំណើរការវិវត្តន៍នៃសាលាក្តីខ្មែរក្រហមនិងព័ត៌មានជុំវិញសាកលលោកដែលទាក់ទងនឹងតុលាការនេះ ។ បន្ទាប់មក កញ្ញា ផល្លា ក៏បានបង្ហាញពីរបៀបនៃការបើកគេហទំព័រ និងពន្យល់ពីផ្នែកនីមួយៗនៅក្នុងគេហទំព័រនេះដើម្បីនិស្សិតមានការងាយស្រួលក្នុងការស្វែងរកអ្វីដែលខ្លួនចង់សិក្សា ។

ជាកិច្ចបញ្ចប់នៃកម្មវិធី លី សុខឃាង បានធ្វើការបញ្ចប់កម្មវិធីទាំងមូល និងបានឆ្លើយតបទៅនឹងសំណួរចុងក្រោយដែលនិស្សិតបានសួរខាងលើទាក់ទងនឹងការដួលរលំនៃរបបខ្មែរក្រហមដោយសារការខ្វះខាតនូវទំនាក់ទំនងការបរទេស ហើយអ្នកដឹកនាំខ្វះចន្លោះប្រហោងក្នុងការដឹកនាំប្រទេសនិងដោយមានភាពសង្ស័យជ្រុលទើបធ្វើឲ្យកើតឡើងនូវការកាប់សម្លាប់គ្នាឯងនិងប្រជាជនស្លូតត្រង់ទាំងអស់ដែលគ្មានកំហុស ។

ជាសរុបមក វេទិកាពិភាក្សានេះអាចធ្វើឲ្យនិស្សិតផ្លាស់ប្តូរនូវទស្សនវិស័យថ្មីមួយ ដោយឲ្យនិស្សិតយល់ពីការប្រើប្រាស់បច្ចេកវិទ្យាថ្មីក្នុងការស្រាវជ្រាវ និងចេះទាញរកអ្វីដែលមានអត្ថប្រយោជន៍ចៀសជាងការប្រើប្រាស់នូវគេហទំព័រកំសាន្តផ្សេងៗ ។ ដូច្នេះការផ្សព្វផ្សាយនូវគម្រោងនេះ គឺចង់ឲ្យកូនខ្មែរជំនាន់ក្រោយ ងាកទៅចាប់អារម្មណ៍នឹងប្រវត្តិសាស្ត្ររបស់ខ្លួន និងដំណើរការកាត់ទោសរបស់មេដឹកនាំខ្មែរក្រហម ។



**ចប់**